ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ: 2149 PEAC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ដេញថ្លៃផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្មពង្រីកខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម 22kV ចេញពីអនុស្ថានីយ៍ អគ្គិសនីស្ទឹងត្រែងចំនួន 02 Feeders មកភ្ជាប់នឹងបណ្តាញដែលមានស្រាប់ក្នុងខេត្តស្ទឹងត្រែង

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបាន ចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើស អ្នកផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្មពង្រីកខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម 22kV ចេញពីអនុស្ថានីយ៍អគ្គិសនីស្ទឹងត្រែង ចំនួន 02 Feeders មកភ្ជាប់នឹងបណ្តាញដែលមានស្រាប់ក្នុងខេត្តស្ទឹងត្រែង ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មាន ដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ វេលាម៉ោង ១៤:០០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៥:០០ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារ ដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី 12 ខែកញ្ញា ឆ្នាំ ២០១៧

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ឆឹង_អ៊ីង

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ